ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងការពារជាតិ
គណៈកម្មការជ្រើសរើសពលទាហាន
បំពេញក្របខណ្ឌឱ្យយោធភូមិភាគទី១
លេខ ១៩៧/ស.ជ.៧
/២០១៧

រាជធានីភ្នំពេញ ថ្ងៃទី០៩ ខែតុលា ឆ្នាំ២០១៧

# សេចក្តីជូនដំណឹង

## ស្តីពីដំណើរការចែកនិងដាក់ពាក្យសុំចូលបម្រើកងយោធពលខេមរភូមិន្ទ ដើម្បីបំពេញក្របខណ្ឌឱ្យយោធភូមិភាគទី១ កងទ័ពជើងគោក

គណៈកម្មការជ្រើសរើសពលទាហានបំពេញក្របខណ្ឌឱ្យយោធភូមិភាគទី១ កងទ័ពជើងគោក មានកិត្តិយសសូមជម្រាបជូនដំណឹងដល់សាធារណជន ជាពិសេសយុវជន ដែលមានបំណងស្ម័គ្រចិត្តចូលបម្រើកងយោធពលខេមរភូមិន្ទ ឱ្យបានជ្រាបថា : ផ្អែកតាមលទ្ធផលដែលគណៈកម្មការជ្រើសរើសទទួលបានមកដល់ពេលនេះឃើញថា ចំនួនបេក្ខជនដែលបានទទួលពាក្យនៅតាមផ្នែកមូលដ្ឋានជ្រើសរើសស្រុក ក្រុង ចំណុះបណ្តាយោធភូមិភាគទាំង ០៦ បានគ្រប់សន្ទស្សន៍ដែលបានកំណត់។

ដោយពិនិត្យឃើញលទ្ធផលនេះ គណៈកម្មការជ្រើសរើស សូមជូនដំណឹងដូចខាងក្រោម៖

១-នៅតាមផ្នែកជ្រើសរើសមូលដ្ឋានស្រុក ក្រុង ចំណុះយោធភូមិភាគទាំង ០៦ ត្រូវបញ្ចប់ការចែកពាក្យចាប់ពីថ្ងៃទី០៨ ខែតុលា ឆ្នាំ២០១៧ នេះតទៅ

២-ចំពោះបេក្ខជនដែលបានទទួលពាក្យរួចហើយ ត្រូវយកទៅបំពេញបែបបទនោះ សូមប្រញាប់ប្រួសរាន់យកពាក្យមកដាក់វិញនៅតាមបណ្តាផ្នែកជ្រើសរើសមូលដ្ឋានកងរាជអាវុធហត្ថស្រុក ក្រុង ឱ្យបានមុនថ្ងៃទី២៥ ខែតុលា ឆ្នាំ២០១៧ ជាកំហិត។

សេចក្តីដូចបានជម្រាបជូនខាងលើនេះ សូមសាធារណជន និងបេក្ខជនទាំងអស់មេត្តាជ្រាបជាព័ត៌មាន និងចូលរួមអនុវត្តន៍ឱ្យបានល្អទៅតាមកម្មវិធីដែលគណៈកម្មការជ្រើសរើសបានកំណត់។

សម្រាប់ព័ត៌មានបន្ថែមសូមទាក់ទងមកក្រុមការងារដែលមានទូរស័ព្ទទំនាក់ទំនងលេខ **085333944 085222744 / 0972666241 / 0972666240 / 086847300 / 086685570**។

**គណៈកម្មការជ្រើសរើសពលទាហាន**